# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ការបង្ហាអំពីប្រល័យពូជសាសន៍ ៖ គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពីការបង្រៀនប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មធ្យមសិក្សា

២៩ មិថុនា-៧ កក្កដា ២០០៩

បណ្ណាល័យព្រឹទ្ធសភា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# អំពីប្រល័យពូជសាសន៍នៅក្នុងបរិបទសាកលលោក

សាស្ត្រាចារ្យ ហ្វ្រែង ឆក

### សេចក្តីផ្តើម

សូមគោរពលោកគ្រូអ្នកគ្រូ អ្នកស្រាវជ្រាវ អ្នករដ្ឋបាល និងមិត្តភក្តិទាំងអស់ជាទីមេត្រី ។ ថ្ងៃនេះជាថ្ងៃដ៏សប្បាយរីករាយជាទីបំផុត ដែលខ្ញុំមានឱកាសចូលរួមជាមួយអ្នកទាំងអស់គ្នា ខណៈពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំយុវជននិងកីឡា បានប្រចបាច់កម្លាំងបញ្ចូលគ្នាដើម្បីដាក់បញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហម ទៅក្នុងកម្មវិធីសិក្សារបស់សាលានៅក្នុងប្រទេសកម្ពុជា ។ វគ្គបណ្តុះបណ្តាលគ្រូបង្រៀននេះ បានសម្គាល់នូវព្រឹត្តិការណ៍ដ៏មានសារសំខាន់លើកទីមួយ នៅក្នុងប្រវត្តិសាស្ត្រអប់រំរបស់កម្ពុជា ។ ខ្ញុំមានកិត្តិយសក្នុងការចែករំលែកបទពិសោធន៍នេះជាមួយអ្នកទាំងអស់គ្នា ។

ប៉ុន្មានឆ្នាំមិនយូរប៉ុន្មានកន្លងទៅនេះ លោក ឌី ខាំបូលី បានមកធ្វើការជាមួយខ្ញុំនៅឯសាកលវិទ្យាល័យ កុងខងដៀ ក្នុងទីក្រុងម៉ុងរ៉េអាល់ ប្រទេសកាណាដា ។ ពួកយើងបានធ្វើការលើសេចក្តីព្រាងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាភាសាអង់គ្លេស ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជូន បូលី ឲ្យមកធ្វើកិច្ចការនេះជាមួយខ្ញុំ ។ អស់រយៈពេលជិត១៣សប្តាហ៍ គឺមានរយៈពេលជិតពេញមួយឆមាស បូលី និងខ្ញុំបានចំណាយជាច្រើនម៉ោងរៀងរាល់សប្តាហ៍នៅក្នុងការិយាល័យរបស់ខ្ញុំ ពិនិត្យមើលយ៉ាងដិតដល់ និងធ្វើការកែតម្រូវទៅលើអត្ថបទ ។ អាកាសធាតុត្រជាក់ក្នុងខែតុលា និងខែវិច្ឆិកាដែលកំពុងតែចូលមកដល់ បានចូលមកផ្លាស់អាកាសធាតុក្តៅនាខែកញ្ញាយ៉ាងឆាប់រហ័ស ។ ស្លឹកឈើបានប្រែទៅជាពណ៌ក្រហមនិងពណ៌លឿងមាស បន្ទាប់មកក៏ជ្រុះចុះមកលើដី ។ ព្រិលនិងភ្លៀងទឹកកកបានថយចុះ ។ បូលី បានពាក់អាវមួយជាន់ហើយមួយជាន់ទៀត ដើម្បីរក្សាកម្តៅពេលធ្វើដំណើរទៅសាកលវិទ្យាល័យកុងខងដៀ ដែលមានចម្ងាយឆ្ងាយនិងផ្លូវរអិល ។ បូលី ញ៉ាំយ៉ាងច្រើនដើម្បីបង្កើនកម្លាំង ។ ជាចុងក្រោយ បូលី បានឆ្លងកាត់រាល់ឧបសគ្គទាំងអស់ ហើយថ្ងៃនេះ យើងកំពុងតែពិភាក្សា

Documentation Center of Cambodia
Searching for the Truth ស្វែងរកការពិត ដើម្បីការចងចាំ និងយុត្តិធម៌
DC-Cam ◆ 66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
Tel: (855-23) 211-875 ◆ Fax: (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

គ្នា ថាតើត្រូវដាក់សៀវភៅរបស់ បូលី ទៅក្នុងទៅក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍នៅក្នុងពិភពលោកដោយរបៀបណា ។

## ការបង្រៀននៅក្នុងសង្គមកាណាដា - ការបង្រៀននៅក្នុងសង្គមកម្ពុជា

ខ្ញុំរស់នៅនិងបង្រៀននៅក្នុងប្រទេសកាណាដា ។ បើឈរលើស្តង់ដារបស់ប្រទេសកម្ពុជា កាណាដាគឺជាប្រទេសអ្នកមាន ។ ពួកយើងភាគច្រើនមានម្ហូបអាហារគ្រប់គ្រាន់ ជម្រកសមរម្យ សម្លៀកបំពាក់ច្រើនសន្ធឹកសន្ធាប់ និងសន្តិសុខផ្ទាល់ខ្លួន ។ យើងអាចទទួលបានថ្នាំពេទ្យនិងវេជ្ជបណ្ឌិតល្អៗ ។ យើងផ្តល់ការអប់រំដល់កូនចៅយើង និងបញ្ជូនកូនប្រុសកូនស្រីយើងជាច្រើនទៅសិក្សានៅតាមមហាវិទ្យាល័យនិងសាកលវិទ្យាល័យនានា ដើម្បីយកសញ្ញាប័ត្រជាន់ខ្ពស់ ដូចជាផ្នែកមនុស្សជាតិ វិទ្យាសាស្ត្រសង្គម វិស្វកម្ម ពាណិជ្ជកម្ម និងវិទ្យាសាស្ត្រខាងជីវសាស្ត្រ ។

នៅក្នុងវិស័យនយោបាយ យើងដែលជាប្រជាជនកាណាដាមានសិទ្ធិនិងកាតព្វកិច្ច ដែលត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញរបស់កាណាដាស្តីពីសិទ្ធិនិងសេរីភាព ។ នៅក្នុងច្បាប់របស់កាណាដា ធម្មនុញ្ញនេះបានផ្តល់ឲ្យយើងនូវសិទ្ធិសំខាន់ៗមួយចំនួនដូចជា ៖

១. សិទ្ធិក្នុងការទទួលបានការប្រព្រឹត្តមកលើស្មើៗគ្នា
២. សិទ្ធិដើរហើរដោយសេរីនៅជុំវិញកាណាដា
៣. សិទ្ធិក្នុងការគិតដោយសេរី
៤. សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី
៥. សិទ្ធិក្នុងការគោរពជំនឿសាសនា ដោយគ្មានការធ្វើទុក្ខបុកម្នេញ
៦. សិទ្ធិក្នុងការប្រមូលផ្តុំដោយសន្តិភាព
៧. សិទ្ធិក្នុងការទទួលបានលិខិតឆ្លងដែន សម្រាប់ការធ្វើដំណើរជាអន្តរជាតិ
៨. សិទ្ធិក្នុងការបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យ ។

យើងក៏មានកាតព្វកិច្ចដូចតទៅ ៖

១. យើងត្រូវយល់និងគោរពច្បាប់របស់កាណាដា ។
២. យើងត្រូវគោរពសិទ្ធិរបស់អ្នកដទៃ ពេលយើងបង្ហាញទស្សនរបស់យើងដោយសេរី ។
៣. យើងមានកាតព្វកិច្ចត្រូវជួយមនុស្សផ្សេងទៀតនៅក្នុងសហគមន៍របស់យើង ។
៤. យើងមិនត្រូវបានអនុញ្ញាតឲ្យអនុវត្តការរើសអើង ឬបង្កអំពើអយុត្តិធម៌ទៅលើអ្នកដទៃ ។
៥. យើងមានកាតព្វកិច្ចត្រូវបង់ពន្ធទៅលើប្រាក់ចំណូល ទៅឲ្យអាជ្ញាធរខេត្តនិងរដ្ឋាភិបាលសហព័ន្ធរបស់យើង ។

៦. ក្នុងករណីសង្គ្រាមឬជម្លោះស៊ីវិល យើងអាចត្រូវបានកេណ្ឌឲ្យបម្រើនៅក្នុងកងទ័ពរបស់ប្រទេសកាណាដា ។

យើងពង្រឹងសិទ្ធិនិងកាតព្វកិច្ចរបស់យើង នៅក្នុងប្រព័ន្ធអប់រំរបស់យើង ។ សាលានៅក្នុងប្រទេសកាណាដា បង្រៀនសិស្សអំពីសីលធម៌វិជ្ជា កេរ្តិ៍ដំណែលជាតិ សីលធម៌ពលរដ្ឋ និងអត្តសញ្ញាណជាតិរបស់យើងដែលមានឈ្មោះខ្ពស់ត្រដែត ។ តើពួកគេមានន័យយ៉ាងដូចម្តេច?

១. សីលធម៌វិជ្ជាបង្រៀនអំពីតម្លៃនៃជីវិត និងកិត្យានុភាពរបស់បុគ្គលម្នាក់ៗ ។

២. កេរ្តិ៍ដំណែលរបស់កាណាដា សង្កត់ធ្ងន់ទៅលើការវិវត្តនៃសិទ្ធិប្រជាធិបតេយ្យនិងការធានាចំពោះបុគ្គល ប្រឆាំងនឹងអំណាចផ្តាច់ការរបស់រដ្ឋាភិបាល ឬប្រឆាំងទៅនឹងការធ្វើទុក្ខបុកម្នេញពីសំណាក់ប្រជាជនភាគច្រើន ។

៣. នៅក្នុងវគ្គសិក្សាពីពលរដ្ឋវិជ្ជា សិស្សសិក្សាអំពីសារសំខាន់ក្នុងនាមជាប្រជាពលរដ្ឋម្នាក់នៅក្នុងសង្គមប្រជាធិបតេយ្យមួយ ។

៤. កេរ្តិ៍ដំណែលជាតិរបស់កាណាដា សង្កត់ធ្ងន់ទៅលើនីតិរដ្ឋនៅក្នុងសង្គមកាណាដា ដែលជាគន្លឹះនៃការការពារសិទ្ធិនិងសេរីភាពរបស់បុគ្គល ដោយជំរុញសិស្សឲ្យធ្វើការប្រៀបធៀបរវាងប្រព័ន្ធនយោបាយប្រជាធិបតេយ្យ និងប្រព័ន្ធនយោបាយមិនមែនប្រជាធិបតេយ្យ ។

ការបង្រៀនអំពីប្រវត្តិវិទ្យានិងសង្គមវិទ្យានៃអំពើប្រល័យពូជសាសន៍ នៅក្នុងប្រទេសកាណាដាបានពង្រឹងតម្លៃទាំងនេះឡើងវិញ ។ នៅពេលចាប់ផ្តើមបង្រៀនសិស្សអំពីសិទ្ធិមនុស្សអំពើប្រល័យពូជសាសន៍និងអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងៗទៀត គ្រូត្រូវបង្ហាញសេចក្តីស្មោះត្រង់ប្រកបដោយបញ្ញាញាណនិងសេចក្តីក្លាហានប្រកបដោយសីលធម៌ ។ មិនមានប្រទេសឬសង្គមណាមួយដែលមិនដែលមានជួបប្រទះការរំលោភសិទ្ធិមនុស្សទាល់តែសោះនោះទេ ។ ប្រទេសកាណាដាក៏ដូចគ្នាដែរ ។ គ្រូត្រូវតែបង្ហាញនូវពេលវេលាទាំងឡាយក្នុងប្រវត្តិសាស្ត្រកាណាដា នៅពេលភាពដ៏ឧត្តុង្គឧត្តមរបស់កាណាដាត្រូវបានបំភ្លេចចោលឬបោកប្រាស់ ដោយសារតែការប្រព្រឹត្តខុសជាលក្ខណៈប្រព័ន្ធរបស់សមាជិកនៃក្រុម ដោយផ្អែកទៅលើពូជសាសន៍ សាសនា វប្បធម៌ ភាសា ភេទ ឬទស្សននយោបាយ ។ កាណាដាបានចាប់ជនជាតិកាណាដាដើមកំណើតជប៉ុនដាក់ក្នុងជំរំឃុំខ្លួន ហើយបានរឹបអូសទ្រព្យសម្បត្តិរបស់ពួកគេ នៅក្នុងកំឡុងពេលនៃសង្គ្រាមលោកលើកទីពីរ ដោយផ្អែកទៅលើការសង្ស័យទាំងស្រុងថា អ្នកទាំងនេះនឹងសហការជាមួយជប៉ុន ។ កាណាដាមិនបានផ្តល់ឱកាសឲ្យអ្នកទាំងនេះការពារខ្លួននៅក្នុងតុលាការតាមផ្លូវច្បាប់នោះទេ ។ ជួនកាល រដ្ឋាភិបាលកាណាដាបានបង្ខំកូនក្មេងជនជាតិដើមឲ្យរៀននៅក្នុងសាលាមួយប្រភេទ ដែលក្មេងទាំងនេះមិនត្រូវបានអនុញ្ញាតឲ្យនិយាយភាសាកំណើតរបស់ខ្លួន ហើយលក្ខខណ្ឌសុខភាពមិនល្អបាន

បណ្តាលឲ្យពួកគេជាច្រើនកើតជំងឺរបេង ។ យើងបានបង្រៀនកូនចៅរបស់យើងថា យើងបានធ្វើអំពើទាំងនេះ ហើយយើងនឹងមិនធ្វើអំពើទាំងនេះម្តងទៀតឡើយ ។

ខ្ញុំបានសង្ខេបអំពីតម្លៃមួយចំនួនដែលបានតម្រង់ទិសដៅដល់សង្គមកាណាដា ។ តើតម្លៃទាំងនេះមានទំនាក់ទំនងជាមួយនឹងសង្គមកម្ពុជានាពេលបច្ចុប្បន្នដែរឬទេ? តើភាពមានទ្រព្យសម្បត្តិរបស់កាណាដានិងភាពក្រីក្ររបស់កម្ពុជា ធ្វើឲ្យតម្លៃរបស់ប្រទេសកាណាដាមិនមានទំនាក់ទំនង ឬមិនសមស្រប សម្រាប់គ្រូបង្រៀនកម្ពុជា និងរបៀបដែលពួកគេបង្រៀនដែរឬយ៉ាងណា? ជាបុគ្គល ខ្ញុំបដិសេធចំពោះការអះអាងនិងជំនឿដែលថា ជាគោលការណ៍ សិទ្ធិមនុស្សគឺមានលក្ខណៈជាសាកល ហើយត្រូវអនុវត្តជាសាកល ។ ខ្ញុំជឿថា ស្ត្រីគួរមានសិទ្ធិស្មើនឹងបុរស ហើយក្រុមភាគតិចផ្នែកនយោបាយនិងសាសនាត្រូវទទួលបានសេរីភាពពលរដ្ឋនិងនយោបាយ ។ ខ្ញុំជឿថា សិទ្ធិមនុស្សមិនមែនជាបាតុភូតវប្បធម៌ទេ ។ វប្បធម៌គឺមិនមានតម្លៃជាសីលធម៌ខ្ពស់ជាងសិទ្ធិមនុស្សដែរ ដោយផ្អែកទៅលើកិត្យានុភាពរបស់បុគ្គលនីមួយៗ ។ សិទ្ធិរបស់ក្រុមមិនមែនសំខាន់ជាងសិទ្ធិរបស់បុគ្គលនោះទេ ។ ក្រុមដែលមិនត្រូវបានគេគោរព ដូចជាស្ត្រី មនុស្សក្នុងវណ្ណៈទាប ឬមនុស្សក្រៅវណ្ណៈក្នុងសង្គមសាសនាព្រាហ្មណ៍ មិនគួរទទួលបាននូវការ ដាក់កំហិតទៅលើតួនាទី បុព្វសិទ្ធិ និងកាតព្វកិច្ចនោះទេ ។ ហើយតម្លៃរបស់ខ្ញុំបង្ហាញអំពីការបង្រៀនពីអំពើប្រល័យពូជសាសន៍នៅក្នុងបរិបទសាកលលោក ។

ទោះជាយ៉ាងនេះក្តី តម្លៃរបស់ខ្ញុំមិនមែនចាំបាច់ត្រូវតែជាតម្លៃរបស់អ្នកនោះទេ ។ អ្នករស់នៅនិងបង្រៀននៅក្នុងសង្គមកម្ពុជា ។ អ្នកដឹងច្រើនជាងខ្ញុំឆ្ងាយណាស់អំពីតម្រូវការនិងការចង់បានរបស់ប្រជាជនកម្ពុជា ។ ខ្ញុំនឹងមិនដាក់តម្លៃរបស់ខ្ញុំឲ្យអ្នកទាំងអស់គ្នាទទួលយកទេ ។ សុន្ទរកថារបស់ខ្ញុំនៅថ្ងៃនេះ គឺត្រូវបានរៀបរៀងឡើង ដើម្បីស្វែងរកវិធីដ៏ល្អបំផុត ក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមទៅឲ្យប្រជាជនកម្ពុជា ។ យើងនឹងរៀនទាំងអស់គ្នាក្នុងនាមជាដៃគូនៅក្នុងការសន្ទនានេះ ។ ការស្តាប់គ្នានិងការចែករំលែកគ្នាទៅវិញទៅមក នឹងជួយឲ្យយើងទទួលបានផលប្រយោជន៍ពីការសន្ទនាប្រកបដោយភាតរភាពនេះ ។ យើងនឹងនិយាយទៅកាន់គ្នាទៅវិញទៅមក ដោយមិនបានដឹងតាំងពីដំបូងមក ថាតើការសន្ទនារបស់យើង នឹងឆ្ពោះទៅកាន់ទិសដៅណាមួយ ។ ហើយដូចជា ព្រីម៉ូ ឡឺវី ដែលជាអ្នកនៅរស់រានមានជីវិតពីជំរំពលកម្មនិងជំរំសម្លាប់មនុស្សនៅ អូសស្វិច និងជាអ្នកដែលសរសេរប្រវត្តិដ៏ល្បីល្បាញបំផុតមួយអំពីហូឡូខសត៍ យើងអាចនិយាយទៅកាន់គ្នាទៅវិញទៅមកបាន ។ ឥឡូវនេះ យើងនឹងចាប់ផ្តើមចូលប្រធានបទ និងសិក្សាទាំងអស់គ្នាអំពី «អំពើប្រល័យពូជសាសន៍ក្នុងបរិបទសាកលលោក» ។

## តើអ្វីទៅជាអំពើប្រល័យពូជសាសន៍? តើអ្វីទៅជាអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ?

បើតាមខ្ញុំយល់ វិធីសាស្ត្ររបស់ខ្ញុំនៅថ្ងៃនេះត្រូវតាក់តែងឡើងទៅតាមតម្រូវការរបស់អ្នកទាំងអស់គ្នា ។ អ្នកបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅក្នុងប្រទេសកម្ពុជា ។ កិច្ចការរបស់ខ្ញុំគឺដាក់បទពិសោធន៍របស់កម្ពុជាទៅក្នុងបរិបទសាកលលោក អំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ ។ ពាក្យប្រល័យពូជសាសន៍បានដាស់ការចងចាំឡើងវិញ នូវការកាប់សម្លាប់ក្នុងទ្រង់ទ្រាយធំនៅក្នុងសតវត្សរ៍ទី២០នេះ ដូចជាអំពើប្រល័យពូជសាសន៍ទៅលើជនជាតិអាមេនៀនៅក្នុងប្រទេស ទួរគី (Turkey) ជនជាតិអ៊ុយក្រែននៅក្រោមរបបស្តាលីនក្នុងសហភាពសូវៀត ការសម្លាប់រង្គាលទៅលើជនជាតិជ្វីហ្វ ក្រោមរបបអ៊ីត្លែរនៅទ្វីបអឺរ៉ុប និងការសម្លាប់ជនជាតិទូតស៊ីនៅក្នុងប្រទេសរ៉ាន់ដា ។ ទោះជាពាក្យ“ប្រល័យពូជសាសន៍” ទើបតែត្រូវបានបង្កើតឡើងដោយលោក រ៉ាហ្វល់ លឹមគិន នៅក្នុងទសវត្សរ៍៤០ក៏ដោយ ក៏ព្រឹត្តិការណ៍ដែលមានអត្ថន័យរបៀបនេះបានកើតមានឡើងតាំងពីដើមដំបូងនៃប្រវត្តិសាស្ត្រ ។

មានហេតុផលជាច្រើន ក្នុងការសម្លឹងមើលឲ្យកាន់តែជិតទៅលើដើមកំណើតនៃអំពើប្រល័យពូជសាសន៍ ។ ទីមួយ មានមនុស្សតិចណាស់ដែលទទួលស្គាល់ថា អំពើនេះត្រូវបានអនុវត្តនៅក្នុងពេញមួយរយៈកាលនៃប្រវត្តិសាស្ត្រ និងនៅគ្រប់ទីកន្លែងទាំងអស់នៃពិភពលោក ។

សូមចាប់ផ្តើមជាមួយនឹងការពិតដែលថា “អំពើប្រល័យពូជសាសន៍” គឺជាបទឧក្រិដ្ឋនៅក្រោមច្បាប់អន្តរជាតិ ។ វាត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា២ នៃអនុសញ្ញាអន្តរជាតិស្តីពីការបង្ការ និងផ្តន្ទាទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដែលត្រូវបានស្នើឡើងនៅឆ្នាំ១៩៤៨ ដោយការបោះឆ្នោតរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ។ អនុសញ្ញានេះត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់អន្តរជាតិ ដោយការផ្តល់សច្ចាប័នពីសំណាក់ប្រទេសជាច្រើនឆ្នាំ១៩៥១ ។ ដូច្នេះ តើមាត្រា២នៃអនុសញ្ញានេះនិយាយថាម៉េច ។ ខាងក្រោមនេះគឺជាអត្ថន័យនៃអនុសញ្ញាជាប្រវត្តិសាស្ត្រនេះ ៖

## មាត្រា២

នៅក្នុងអនុសញ្ញានេះ ការប្រល័យពូជសាសន៍មានន័យថា ជាអំពើណាមួយក្នុងចំណោមអំពើទាំងប៉ុន្មានខាងក្រោមនេះ ហើយដែលត្រូវតែបានធ្វើឡើងក្នុងបំណងបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិមួយ ជនជាតិមួយ ពូជសាសន៍មួយ ឬក្រុមសាសនាមួយដូចជា ៖

ក. សម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម

ខ. បង្កការខូចខាតផ្នែកសរីរាង្គកាយ ឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម

គ. បង្កឡើងដោយចេតនា នូវស្ថានភាពរស់នៅរបស់ក្រុម ដែលនាំដល់ការបំផ្លិចបំផ្លាញរូបរាងកាយក្រុមទាំងមូល ឬក៏មួយផ្នែក

ឃ. ដាក់បន្ទុកវិធានការនានា សំដៅឃាត់កំណើតទារកនៅក្នុងក្រុម

ង. ផ្ទេរទាំងបង្ខំនូវពួកកុមារៗ របស់ក្រុមមួយទៅក្រុមមួយទៀត ។

និយមន័យនៃអំពើប្រល័យពូជសាសន៍របស់អង្គការសហប្រជាជាតិ គឺជាលទ្ធផលនៃការធ្វើសម្បទានឲ្យគ្នាទៅវិញទៅមកក្នុងចំណោមប្រទេសមហាអំណាច ក្នុងកំឡុងពេលនៃសង្គ្រាមត្រជាក់ ។ អនុសញ្ញាដាក់អំពើទាំងឡាយថាជាបទឧក្រិដ្ឋ ដើម្បីស្វែងរកតែការបំផ្លាញទៅលើក្រុមជាតិមួយ ជនជាតិមួយ ពូជសាសន៍មួយ ឬក្រុមសាសនាមួយតែប៉ុណ្ណោះ ។ អនុសញ្ញានេះបានដកចេញនូវក្រុមផ្សេងៗទៀតដូចជា ក្រុមសេដ្ឋកិច្ច ក្រុមនយោបាយ និងក្រុមសង្គមជាដើម ។ ទោះជាយ៉ាងនេះក្តី ក្រុមទាំងនេះ ឥឡូវនេះស្ថិតនៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលជាប់ទាក់ទងទៅនឹង«ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» ។ លក្ខន្តិកៈនេះរួមបញ្ចូលទាំងអំពើឧក្រិដ្ឋទាំងឡាយដូចជា ការធ្វើទុក្ខបុកម្នេញ ការសម្លាប់រង្គាល ការនិរទេស និងការរំលោភ ដោយផ្អែកទៅលើក្រុមនយោបាយឬសង្គម ដែលមានលក្ខណជាប្រព័ន្ធនិងធំធេង ។

រដ្ឋអាជ្ញាបច្ចុប្បន្នចូលចិត្តកាត់ទោស«ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» ជាង«ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» ។ នេះគឺដោយសារថា ការកាត់ទោសពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាកិច្ចការដ៏លំបាកបំផុត ដែលពួកគេមិនដែលជួបប្រទះ ។ តម្រូវការគន្លឹះសម្រាប់កាត់ទោសអ្នកណាម្នាក់នៅក្រោមអនុសញ្ញារបស់អង្គការសហប្រជាជាតិ គឺភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ ដែលបង្ហាញថាជនដៃដល់មានបំណងឧក្រិដ្ឋ ក្នុងការបំផ្លាញទាំងស្រុងមួយ ឬដោយផ្នែក ។ ប្រសិនបើជនដៃដល់បន្សល់ទុកនូវឯកសារបង្ហាញពីបំណងឧក្រិដ្ឋរបស់ខ្លួន កិច្ចការនេះនឹងមានលក្ខណងាយស្រួលជាងច្រើនណាស់ ។ ប៉ុន្តែភាពវឹកវរបៀបនេះកម្រមានណាស់ ។ ដូច្នេះ រដ្ឋអាជ្ញានៃករណីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ជាញឹកញយត្រូវកសាងបំណងឧក្រិដ្ឋរបស់ជនដៃដល់ ពីសកម្មភាពទាំងឡាយរបស់ជនដៃដល់ ហើយកិច្ចការនេះមានការលំបាកណាស់នៅក្នុងតុលាការ ។ វាមានលក្ខណសាមញ្ញជាងច្រើន ក្នុងការបង្ហាញការធ្វើទុក្ខបុកម្នេញ ការសម្លាប់រង្គាល និងការនិរទេស ដែលធ្វើឡើងចំពោះបុគ្គល ដោយផ្អែកទៅលើសមាជិកភាពរបស់ពួកគេនៅក្នុងគណបក្សនយោបាយមួយ វណ្ណៈសង្គមមួយ ឬក្រុមផ្សេងៗទៀត ដូចជាក្រុមដែលបានកំណត់ដោយជាតិ ជនជាតិ ពូជសាសន៍ និងសាសនា ។ ដោយប្រើប្រាស់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អ្នកមិនចាំបាច់បង្ហាញពីបំណង ក្នុងការបំផ្លាញក្រុមមួយនោះទេ ។

អ្នកស្រាវជ្រាវនិងអ្នកច្បាប់ជំនាញខាងឧក្រិដ្ឋកម្មអន្តរជាតិកាន់តែច្រើនឡើងៗ នៅពេលសព្វថ្ងៃនេះ បានចាត់ទុកអំពើប្រល័យពូជសាសន៍ជាផ្នែកមួយនៃឧក្រិដ្ឋកម្មដែលពួកគេឲ្យឈ្មោះថា «ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ» ។ ឧក្រិដ្ឋកម្មប្រភេទនេះរួមបញ្ចូលទាំង ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមធ្ងន់ធ្ងរ ។ ពួកគេបានកត់សម្គាល់ឃើញថា អំពើប្រល័យពូជសាសន៍

ជាញឹក ញយចាប់ផ្តើមពីវិបត្តិកម្មសង្គ្រាមធ្ងន់ធ្ងរ និងវិបត្តិកម្មប្រឆាំងនឹងមនុស្សជាតិ ។ បទពិសោធន៍បានបង្រៀនថា ជាទូទៅ អំពើប្រល័យពូជសាសន៍ផ្តើមចេញមួយជំហានម្តងៗ ពីការធ្វើទុក្ខបុកម្នេញការ សម្លាប់រង្គាល ការនិរទេស និងការបោសសម្អាតក្រុមជនជាតិ ។

## អំពើប្រល័យពូជសាសន៍នៅក្នុងប្រវត្តិសាស្ត្រ

### ក. ការកសាងនិងរក្សាអាណាចក្រ

ទោះបីជាពាក្យ “ប្រល័យពូជសាសន៍” ទើបតែបង្កើតឡើងនៅពាក់កណ្តាលសតវត្សរ៍ទី២០ក្តី ពាក្យនេះបានពណ៌នាពីបាតុភាពមួយ ដែលមានចំណាស់ស្មើនឹងប្រវត្តិសាស្ត្រដែលត្រូវបានចងក្រងទុក ។ អំពើប្រល័យពូជសាសន៍កើតឡើងជាធម្មតា នៅក្នុងអរិយធម៌បុរាណរបស់ប្រទេសអេហ្ស៊ីប ។ ជនជាតិអាសីរីយាន បានអះអាងថាបានប្រព្រឹត្តអំពើនេះ ហើយករណីជាច្រើនត្រូវបានរកឃើញនៅក្នុងគម្ពីរប៊ីបចាស់ ។ ដើមកំណើតនៃអំពើប្រល័យពូជសាសន៍ហ៊ុមព័ទ្ធទៅដោយអតីតកាល ដែលមិនត្រូវបានកត់ត្រា ។ ប៉ុន្តែ ដោយនៅក្នុងអតីតកាល អំពើប្រល័យពូជសាសន៍តែងតែត្រូវបានរាយការណ៍ភ្ជាប់ជាមួយនឹងសង្គ្រាម យើងអាចធ្វើការទស្សទាយអំពីដើមកំណើតរបស់វាបាន ។ ទីក្រុង រដ្ឋ និងអាណាចក្រមានទំហំតូចណាស់ បើប្រៀបធៀបទៅនឹងស្តង់ដារទំនើបនាពេលបច្ចុប្បន្ន ។ ទីក្រុង រដ្ឋ និងអាណាចក្រទាំងនោះមានទីតាំងនៅតំបន់ ដែលមានឈ្មោះថា ហ្វឺតថាល ក្រេសសិន (Fertile Crescent) ដែលស្ថិតនៅក្នុងតំបន់មជ្ឈិមបូព៌ានាពេលបច្ចុប្បន្ន ។ ជ្រលងនៃតំបន់ Tigris និង Euphrates គឺជាតំបន់មានជីវជាតិ និងមានព្រំដែនធម្មជាតិតែបន្តិចបន្តួចប៉ុណ្ណោះ ។ តំបន់នេះលាតសន្ធឹងឆ្លងកាត់ផ្លូវដែលភ្ជាប់ទ្វីបអាស៊ី អឺរ៉ុប និងអាហ្វ្រិក ។ ជ្រលងតាមដងទន្លេ នីល ក៏មានសណ្ឋានប្រហាក់ប្រហែលនេះដែរ ។ ដូច្នេះឱកាសសម្រាប់ការប្រកួតប្រជែង និងជម្លោះដែលអាចនាំទៅដល់សង្គ្រាមហាក់ដូចជាតែងតែកើតមានឡើងជានិច្ច ។ ទោះជាយ៉ាងនេះក្តី ពីដំបូងឡើយ សង្គ្រាមទាំងនេះមិនបានបង្កើតឲ្យមានអ្វីនោះទេ ។ ក្រុមបរាជ័យបានវិលត្រឡប់ទៅផ្ទះវិញ ធ្វើការជ្រើសរើស និងហ្វឹកហាត់កងទ័ពមួយទៀត ។ ពួកគេផលិតអាវុធបន្ថែម ហើយជួនកាលល្អជាងមុនទៅ ។ បន្ទាប់មក ពួកគេនឹងវិលត្រឡប់មកធ្វើការវាយប្រហារនៅក្នុងសង្គ្រាមថ្មីមួយ ដើម្បីយកមកវិញនូវអ្វីដែលពួកគេបានបាត់បង់ និងធ្វើការសងសឹក ។ វាមិនចាំបាច់ធ្វើការស្រមៃច្រើនទេ សម្រាប់មនុស្សម្នាក់ក្នុងការសម្រេចថា វិធីតែមួយគត់ក្នុងការរក្សាជ័យជម្នះ គឺសម្លាប់រង្គាលសត្រូវឲ្យរលាយសាបសូន្យទាំងអស់ គឺមិនមែនត្រឹមតែកងចម្បាំងប៉ុណ្ណោះទេ ។ យើងគិតថា វិធីសាស្ត្រក្នុងការបញ្ចប់យុទ្ធនាការជ័យជម្នះ មានរយៈកាលប្រហែលមួយពាន់ឆ្នាំនៅក្នុងប្រទេសអេហ្ស៊ីប ។ ការផ្លាស់ប្តូរនេះមិនមែនកើតឡើង ដោយសារការ

កើតមានឡើងនៃការខ្វល់ខ្វាយពីបញ្ហាមនុស្សធម៌នោះទេ ប៉ុន្តែដោយសារការមើលឃើញថា ជនរងគ្រោះដែលនៅរស់មានតម្លៃជាងការដែលពួកគេស្លាប់ ។

ដូចប្រទេសកម្ពុជាក្នុងបុរាណកាលដែរ រដ្ឋទាំងឡាយនៅក្នុងតំបន់ Fertile Crescent ប្រើប្រាស់កម្លាំងពលកម្មច្រើន ពីព្រោះជ្រលងប្រកបដោយជីវជាតិរបស់ពួកគេ តម្រូវឲ្យមានប្រព័ន្ធធារាសាស្ត្រយ៉ាងល្អ ពីព្រោះព្រះជាម្ចាស់ជាច្រើនដែលពួកគេគោរពបូជាតម្រូវឲ្យមានការសាងសង់ប្រាសាទជាច្រើន ហើយដោយមានអ្នកដឹកនាំតិចតួចណាស់ ដែលពេញចិត្តនឹងរាជវាំងរបស់អ្នកដឹកនាំជំនាន់មុន ។ ហេតុដូច្នេះហើយ មេដឹកនាំបានចំណាយធនធានយ៉ាងសម្បើម ដើម្បីលើកតម្កើងរបបគ្រប់គ្រងរបស់ខ្លួន ។ ដូចនេះ ការយល់ដឹងថ្មីមួយដែលថា ចំណាប់ខ្មាំងមានតម្លៃប្រើប្រាស់ក្នុងនាមជាទាសករជាងសាកសព បានរីករាលដាលពេញក្នុងតំបន់នេះ ។

អំពើប្រល័យពូជសាសន៍ត្រូវបានបន្តអនុវត្តដោយរដ្ឋនិងអាណាចក្រ ដោយហេតុផលបីយ៉ាង ៈ

១. ដើម្បីកម្ទេចចោលនូវការគំរាមកំហែងពិតប្រាកដឬដែលបានដឹងមុន

២. ដើម្បីបំភិតបំភ័យសត្រូវពិតប្រាកដឬដែលអាចមើលឃើញ

៣. ដើម្បីទទួលបានធនធានសេដ្ឋកិច្ច ដែលជារបស់អ្នកដទៃ ប៉ុន្តែមិនអាចដណ្តើមយកមកបានតាមរយៈការប្លន់ ។

គោលបំណងទាំងបីនេះ ជាធម្មតាកើតឡើងក្នុងពេលដំណាលគ្នា ទោះបីជាមួយក្នុងចំណោមនេះមានភាពលើសលុបជាងគោលបំណងផ្សេងទៀត នៅក្នុងស្ថានភាពជាក់លាក់ណាមួយ ។

ប្រវត្តិនៃអាណាចក្រ រហូតមកទល់នឹងរយៈកាលសម័យទំនើប ត្រូវបានកត់សម្គាល់ដោយការធ្វើទុក្ខបុកម្នេញតាមកាលវេលា ដែលជួនកាលរីកធំឡើងទៅជាអំពើប្រល័យពូជសាសន៍ ដែលប្រព្រឹត្តឡើងដើម្បីកសាងអាណាចក្រឬរក្សាអាណាចក្រ ។ ចរិតលក្ខណៈដ៏សំខាន់មួយនៃប្រភេទអំពើប្រល័យពូជសាសន៍នេះគឺថា ក្រុមជនរងគ្រោះតែងតែស្ថិតនៅក្រៅពីសង្គមរបស់ជនដៃដល់ ។ យុទ្ធនាការរបស់ទីក្រុង Athens ប្រឆាំងនឹងទីក្រុង Melos យុទ្ធនាការរបស់ទីក្រុង Rome ប្រឆាំងនឹងទីក្រុង Carthage យុទ្ធនាការរបស់ Genghis Khan ប្រឆាំងនឹងប្រជាជនជាច្រើន និងយុទ្ធនាការរបស់ពួក Crusaders ប្រឆាំងនឹងប្រជាជននៃទីក្រុង Antioch និង Jerusalem អាចជាឧទាហរណ៍ ។

## ខ. ដើម្បីអនុវត្តជំនឿ មនោគមន៍វិជ្ជា ឬ ទ្រឹស្តី

ចាប់ផ្តើមជាមួយនឹងបូជនីយកិច្ច ធាតុផ្សំថ្មីមួយដែលលេចធ្លោជាងគេនៅក្នុងសតវត្សរ៍ទី២០ នេះគឺអំពើប្រល័យពូជសាសន៍ត្រូវបានធ្វើឡើង ដើម្បីអនុវត្តជំនឿ មនោគមន៍វិជ្ជា ឬទ្រឹស្តី ។ បូជនីយកិច្ចដើម្បី ដណ្តើមយកដែនដី ប៉ាឡេស្ទីន ជាថ្មីម្តងទៀត ក៏ដូចជាបូជនីយកិច្ចរបស់ជនជាតិ

Albigensia នៅភាគ ខាងត្បូងប្រទេសបារាំងគឺជាសញ្ញាដំបូងមួយ ដែលគោលបំណងក្នុងការពង្រីកអាណាចក្រ និងផ្សព្វផ្សាយជំនឿកើតឡើងព្រមគ្នា ។ នៅចុងសតវត្សរ៍ទី១១ក្រុមអ្នកចម្បាំងបានចាប់ផ្តើមយុទ្ធនាការដើម្បីផ្តល់សេរីភាពដល់ដែនដីពិសិដ្ឋពីពួកអត់សាសនា ។ នៅពេលពួកគេលុកលុយដែនដី Jerusalem ពួកគេបានសម្លាប់រង្គាលប្រជាជនដែលមិនមែនជាគ្រិស្តសាសនិកទាំងអស់ ។ ប៉ុន្តែពួកគេក៏បានបន្តរស់នៅទីនោះ ដើម្បីបង្កើតរាជាណាចក្រនិងប្រមូលយកទ្រព្យសម្បត្តិ ។ នៅដើមសតវត្សរ៍ទី១៣ Languedoc (សព្វថ្ងៃ ស្ថិតនៅភាគខាងត្បូងប្រទេសបារាំង) ដែលជាតំបន់រុងរឿងជាងគេបំផុតនៅទ្វីបអឺរ៉ុបត្រូវបានបំផ្លាញដោយពួកអ្នកវាយប្រហារជនជាតិ Albigensia ។ បុព្វជិតសាសនាបានចោទប្រកាន់ពួកអភិជននៅតំបន់ Languedoc ជាមួយនឹងពាក្យចចាមអារាម ដែលគំរាមកំហែងដល់អាជ្ញាធរទីក្រុងរ៉ូម ហើយបានយាងព្រះមហាក្សត្របារាំង ឲ្យរៀបចំការវាយប្រហារទៅលើក្រុមជនដែលប្រឆាំងនឹងជំនឿសាសនាគ្រិស្ត ។ គាត់បានធ្វើរឿងនេះប្រកបដោយប្រសិទ្ធភាពបំផុត ដែលធ្វើឲ្យតំបន់នោះមិនអាចងើបឡើងវិញបាន ។ ខណៈពេលដែលក្រុមអ្នកប្រឆាំងសាសនាគ្រិស្តនិងបក្សពួករបស់ខ្លួនត្រូវបានកម្ទេចចោលតំបន់ នោះក៏ត្រូវបានបញ្ចូលទៅក្រោមការគ្រប់គ្រងរបស់រាជាណាចក្របារាំង ។

អំពើប្រល័យពូជសាសន៍ដែលធ្វើឡើងដើម្បីមនោគមន៍វិជ្ជាសុទ្ធសាធដំបូងបំផុត ប្រហែលជាការធ្វើទុក្ខបុកម្នេញទៅលើអ្នកកាន់សាសនាគ្រិស្ត នៅក្នុងប្រទេសជប៉ុនក្នុងសតវត្សរ៍ទី១៧ ។ តុលាការ Togkugawa បានប្រឈមមុខទៅនឹងការបះបោរពីរឿងពន្ធដារ ពីសំណាក់អ្នកចូលសាសនាគ្រិស្តក្នុងឆ្នាំ ១៦៣៧ ។ ដោយត្រូវបានគេហៅថាការបះបោរ Shimabara តុលាការ Togkugawa បានកម្ទេចពួកអ្នកបះបោរ និងបានបន្តទៅសម្លាប់រង្គាលអ្នកទាំងឡាយណា ដែលមិនព្រមបោះបង់ចោលជំនឿសាសនាគ្រិស្តរបស់ខ្លួន ។ ពួកគេក៏បានដកជនបរទេសចេញពីប្រទេសជប៉ុន ក្នុងរយៈពេលពីររយឆ្នាំក្រោយមកទៀត ។

ពេលយើងចូលមកដល់សតវត្សរ៍ទី២០ គ្រប់អំពើប្រល័យពូជសាសន៍ធំៗទាំងអស់ត្រូវបានធ្វើឡើងដើម្បីពង្រឹងមនោគមន៍វិជ្ជា ។ នៅទីនេះ ក្រុមជនរងគ្រោះតែងតែមានទីតាំងនៅក្នុងសង្គមជាមួយនឹងជនដៃដល់ទាំងការរស់នៅទាំងទំនាក់ទំនងក្នុងសង្គម ។ ជាពិសេសជាងនេះទៅទៀត អំពើប្រល័យពូជសាសន៍ទាំងនេះត្រូវបានប្រព្រឹត្តឡើង ដោយការចំណាយយ៉ាងសម្បើមរបស់សង្គមជនដៃដល់ ទាំងការចំណាយផ្នែកសង្គមកិច្ចនិងសេដ្ឋកិច្ច ។ ប្រភេទនេះខុសពីអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តឡើងពង្រីកនិងថែរក្សាអាណាចក្រ ។ អំពើប្រល័យពូជសាសន៍ប្រភេទនេះផលិតផលប្រយោជន៍ជាក់ស្តែងឲ្យជនដៃដល់ ដូចជាការលុបបំបាត់ការគំរាមកំហែង បំភិតបំភ័យខ្លាំង និងការទទួលបាននូវទ្រព្យសម្បត្តិ ។ វាគួរឲ្យកត់សម្គាល់ដែលថា ប្រការនេះគឺមិនពិតទេសម្រាប់អំពើប្រល័យពូជសាសន៍ទៅលើ

ជនជាតិ អាមីនៀ ហូឡូខសត៍ ការសម្លាប់រង្គាលទៅលើក្រុមជាច្រើនក្រោមរបប ស្តាលីន និងការសម្លាប់រង្គាលប្រជាជនកម្ពុជាដែលរស់នៅតាមទីក្រុងដោយខ្មែរក្រហម ។ ក្នុងករណីអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដា ប្រឆាំងនឹងជនជាតិទូតស៊ីក្នុងឆ្នាំ១៩៩៤ ខណៈពេលដែលមានការអះអាងថាពួកទូតស៊ីមានការគំរាមកំហែងដល់ការរស់រានរបស់ពួក ហ៊ូទូ ជនរងគ្រោះភាគច្រើន គឺជាកសិករ អ្នកធ្វើការងារ និងជនដែលគ្មានអាវុធជាតិទូតស៊ី គឺមិនក្រុមទូតស៊ី ដែលបានឈ្លានពានរ៉្វាន់ដាដើម្បីដណ្តើមយកជីវិញនោះទេ ។ ជាងនេះទៅទៀត ថ្នាក់ដឹកនាំដែលជាជនដៃដល់គឺជាក្រុមហ៊ូទូ ដែលស្ថិតនៅក្នុងរដ្ឋាភិបាលរ៉្វាន់ដា ។ ពួកគេបានអះអាងអំពីឧត្តមភាពរបស់ហ៊ូទូ និងពីភាពចង្រៃរបស់ពួកទូតស៊ី ដែលតម្រូវឲ្យមានការកម្ទេចចោល ។

មានទម្រង់ជាច្រើនដែលអំពើប្រល័យពូជសាសន៍បែបមនោគមន៍វិជ្ជា មានលក្ខណៈប្រហាក់ប្រហែលគ្នា ៖

១. ពួកគេបញ្ចុះតម្លៃបុគ្គលដើម្បីប្រយោជន៍រួម និងបដិសេធលទ្ធិប្រជាធិបតេយ្យនិងជនទាំងឡាយណាដែលឲ្យតម្លៃទៅលើមនុស្សជាតិ ។
២. ពួកគេបូជាចំពោះមធ្យោបាយដើម្បីសម្រេចបានលទ្ធផលចុងក្រោយ ជាពិសេសការសម្លាប់ ដើម្បីសម្រេចបាននូវគោលដៅនយោបាយ ។
៣. ពួកគេបដិសេធនីតិរដ្ឋ តាមរយៈការគោរពរដ្ឋធម្មនុញ្ញ ឬដើម្បីឯករាជ្យភាពនៃតុលាការនិងចៅក្រម ។
៤. ពួកគេមិនផ្តល់សច្ចាប័នបសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅខែធ្នូឆ្នាំ១៩៤៨ ។

## កម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍

ការពិនិត្យមើលដោយសង្ខេបទៅលើប្រវត្តិនៃអំពើប្រល័យពូជសាសន៍ អនុញ្ញាតឲ្យយើងដាក់ការគ្រប់គ្រងរបស់ខ្មែរក្រហមនិងលទ្ធផលនៃរបបនេះ ទៅក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរដទៃទៀត បានទូលំទូលាយជាងមុន ។ អត្ថន័យមួយចំនួនបានលេចឡើង ៖

១. ព្រឹត្តិការដើមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាភាពផ្សេងៗគ្នានៃដំណើរស្វែងរកសង្គមល្អឥតខ្ចោះមួយ នៃមនោគមន៍វិជ្ជាម៉ាក្ស-លេនីន និងម៉ៅ ។ ដោយផ្អែកលើមនោគមន៍វិជ្ជានេះ បក្សរបស់ខ្មែរក្រហមបានអនុវត្តនូវការពិសោធន៍ដ៏ធំធេង ក្នុងការកសាងសង្គមក្នុងគោលបំណងលុបបំបាត់អតីតកាល ដើម្បីកសាងអនាគតល្អឥតខ្ចោះមួយ ។ ពាក្យស្លោកនៅក្នុងការចាប់ផ្តើមប្រវត្តិសាស្ត្រគឺការបង្វិលពេលវេលាមកកាន់ “ឆ្នាំសូន្យ” ដែលជាគោលដៅច្បាស់លាស់មួយ ។ គោលដៅសម្រាប់

អនាគតល្អឥតខ្ចោះមួយតម្រូវឲ្យមានការបញ្ជូនអ្នករស់នៅក្នុងក្រុងភ្នំពេញយ៉ាងសាហាវព្រៃផ្សៃទៅកាន់ទីជនបទ និងការចាប់ផ្តើមដាក់ឲ្យមាននូវវិធានការបង្ខំឲ្យប្រជាជនធ្វើការជាទម្ងន់ ដើម្បីអនុវត្តនូវគំនិតវើរវាយដែល គ្មានហេតុផលរបស់ខ្មែរក្រហម ក្នុងការកសាងប្រព័ន្ធធារាសាស្ត្រដ៏ច្រើនសន្ធឹកសន្ធាប់ ដើម្បីដាំដុះស្រូវរៀងរាល់ឆ្នាំ ។ ដំណើរការស្វែងរកសង្គមល្អឥតខ្ចោះនេះ ក៏ត្រូវបានមើលឃើញតាមរយៈគោលនយោបាយរបស់ខ្មែរក្រហម ក្នុងការគូសបន្ទាត់រវាង "ប្រជាជនចាស់" នៅទីជនបទ និង"ប្រជាជនថ្មី" ដែលត្រូវបាននិរទេសពីទីក្រុង ។ "ប្រជាជនថ្មី" ដែលមានបាតដៃទន់និងមានគំនិតទោរទៅរកខាងបស្ចិមប្រទេសប្រកបដោយភាពពុករលួយ ត្រូវបានប្រព្រឹត្តមកលើក្នុងនាមជាជនភាគតិចដែលជីវិតរបស់អ្នកទាំងនេះនឹងអាចត្រូវបាត់បង់គ្រប់ពេលវេលាទាំងអស់ ។
"ប្រជាជនចាស់" មើលឃើញប្រជាជនថ្មីថាបាន រំលោភទៅលើច្បាប់ថ្មី ។

២. ការឡើងកាន់អំណាចរបស់ខ្មែរក្រហម កើតឡើងប្រឆាំងនឹងដំណើរនៃបដិវត្តន៍និងសង្គ្រាម ។ ពួកគេចាប់ផ្តើមដណ្តើមការកាន់កាប់ប្រទេសកម្ពុជាក្នុងកំឡុងពេលនៃសង្គ្រាមវៀតណាម ហើយទទួលបានជំនួយយោធាយ៉ាងច្រើនសន្ធឹកសន្ធាប់ពីកុម្មុយនីស្តវៀតណាម ។ សង្គ្រាមបម្រើដល់ភាពត្រឹមត្រូវនៃអំពើព្រៃផ្សៃ ដែលរួមមានការសម្លាប់មន្ត្រីរបស់ លន់ នល់ ។ ស្ថានភាពនៃសង្គ្រាមក៏បម្រើដល់ការសម្ងាត់ជុំវិញបញ្ហាថាតើអ្នកណាដឹកនាំអង្គការ និងកន្លែងរស់នៅរបស់មេដឹកនាំខ្មែរក្រហម ។

៣. ដោយផ្អែកទៅលើការស្វែងរកសង្គមល្អឥតខ្ចោះរបស់ពួកគេ និងការចាប់ផ្តើមប្រវត្តិសាស្ត្រជាថ្មីម្តងទៀត ខ្មែរក្រហមបានបដិសេធនូវតម្លៃនៃវប្បធម៌ជាប្រពៃណី ដែលពួកគេមើលឃើញថាមានសារសំខាន់ក្នុងការទទួលបានការអភិវឌ្ឍ ។ នៅក្រោមការបែងចែកជាថ្មីរបស់ពួកគេ សមាជិកគ្រួសារទាំងអស់នឹងលែងគោរពអំណាចរបស់ឪពុកម្តាយ ។ អង្គការបានដាក់ជំនួសអំណាចរបស់ឪពុកម្តាយឲ្យនៅក្រោមបញ្ជារបស់ខ្លួន ហើយបានប្រែក្លាយកុមារឲ្យទៅជាអ្នកយកការណ៍ពីឪពុកម្តាយទៅវិញ ។ ការគោរពចាស់ទុំនិងការអនុវត្តកសិកម្មបែបបុរាណ ក៏បានក្លាយទៅជាជនរងគ្រោះនៃការស្វែងរកអនាគតល្អឥតខ្ចោះរបស់ខ្មែរក្រហមផងដែរ ។ លទ្ធផលគឺជាគ្រោះមហន្តរាយមួយ ។ ប្រជាជនសាមញ្ញជួបនូវគ្រោះទុរ្ភិក្សនិងជំងឺ ។

៤. ដូច ស្តាលីន និង ម៉ៅ ដែរ ប៉ុល ពត បានបង្កើតខ្មាំងបង្កប់និងពួកវិទ្ធង្សនា ដើម្បីពន្យល់អំពីបរាជ័យរបស់គាត់ចំពោះផែនការសេដ្ឋកិច្ច និងបង្ហាញពីភាពត្រឹមត្រូវនៃការអនុវត្តអំពើឃោរឃៅរបស់អង្គការ ដែលផ្តោតទៅលើវិសុទ្ធកម្មក្នុងទ្រង់ទ្រាយធំ នៅក្នុងជួរបក្សនិងអំពើអំពើឃោរឃៅនៅភូមិភាគបូព៌ា ។ រាល់ការងាករេចេញពីបញ្ជានិងជំនឿរបស់អង្គការ ដូចជាការរិះគន់ទៅលើភាពរឹងរូសនិងកម្មវិធីដែលគ្មានភាពប្រាកដនៅជនបទជារបស់បក្ស នឹងត្រូវចោទប្រកាន់ពីបទងាករេ ។

៥. ប៉ុល ពត និយាយពន្យើសជាប់ជានិច្ចអំពីការគំរាមកំហែងរបស់ត្រូវបរទេស ដូចដែលស្តាលីន អ៊ីត្លែរ និង ម៉ៅ ធ្វើដូច្នេះដែរ ដើម្បីបង្ហាញពីភាពត្រឹមត្រូវរបស់ខ្លួនក្នុងការប្រព្រឹត្តអំពើឃោរឃៅបន្ទាប់ពីចុងបញ្ចប់នៃសង្គ្រាម និងដើម្បីពន្យល់ពីតម្រូវការក្នុងការដាក់ប្រទេសកម្ពុជា ឲ្យនៅដាច់ពីពិភពលោក ។ ដោយឈរលើមូលហេតុនេះ ប៉ុល ពត បដិសេធមិនទទួលយកជំនួនបរទេសពីប្រទេសចក្រពត្តិនិយមនិងសង្គមនិយម បដិសេធមិនព្រមទទួលយកការដឹកជញ្ជូនថ្នាំដែលត្រូវការចាំបាច់ដើម្បីព្យាបាលជំងឺ និងបដិសេធមិនព្រមទទួលយកអាហារដើម្បីប្រយុទ្ធប្រឆាំងនឹងគ្រោះទុរ្ភិក្សដែលបានបណ្តាលឲ្យប្រជាជនកម្ពុជារាប់រយពាន់នាក់ស្លាប់បាត់បង់ជីវិត ។

## *តើវាជាបញ្ហាសម្រាប់សិស្សរបស់អ្នកដែរឬទេ ប្រសិនបើខ្មែរក្រហមប្រព្រឹត្តខក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬប្រព្រឹត្តអំពើឧក្រិដ្ឋធ្ងន់ធ្ងរដទៃទៀត?*

ឥឡូវនេះ អ្នកដឹងថាដើម្បីកាត់ទោសអ្នកណាម្នាក់ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ តម្រូវឲ្យមានភ័ស្តុតាងគ្រប់គ្រាន់ ដើម្បីបង្ហាញថាពួកគេមានបំណងចង់បំផ្លាញក្រុមជាតិ ជនជាតិ ជាតិសាសន៍ ឬសាសនាណាមួយ ។ ម្យ៉ាងវិញទៀត អ្នកក៏បានដឹងដែរថា វាអាចធ្វើទៅបានក្នុងការកាត់ទោសអ្នកណាម្នាក់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចំពោះការសម្លាប់ធ្វើទុក្ខបុកម្នេញពួកគេក្នុងនាមជាបុគ្គលដោយសារតែពួកគេជាសមាជិកនៃក្រុមនយោបាយឬសង្គមណាមួយ បន្ថែមពីលើសមាជិកភាពរបស់ពួកគេនៅក្នុងក្រុមជាតិ ជនជាតិ ជាតិសាសន៍ ឬសាសនាណាមួយ ។ សូមចងចាំថា ការសម្លាប់ជនស៊ីវិលស្លូតត្រង់ ដោយសារតែពួកគេស្ថិតនៅក្នុងវណ្ណៈសង្គមណាមួយ គឺស្ថិតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប៉ុន្តែមិនស្ថិតនៅក្នុងអនុសញ្ញាប្រល័យពូជសាសន៍របស់អង្គការសហប្រជាជាតិទេ ។ ហើយក៏សូមចងចាំដែរថា ការសម្លាប់ជនស្លូតត្រង់ ដោយសារតែពួកគេស្ថិតនៅក្នុងក្រុមនយោបាយណាមួយ គឺស្ថិតនៅក្នុងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប៉ុន្តែមិនស្ថិតនៅក្នុងអនុសញ្ញាប្រល័យពូជសាសន៍របស់អង្គការសហប្រជាជាតិទេ ។ រហូតមកទល់នឹងថ្ងៃនេះ ការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនទាន់បានចោទប្រកាន់ជនជាប់ចោទណាម្នាក់ជាមួយឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅឡើយទេ ។ ទោះជាយ៉ាងនេះក្តី សូមកត់សម្គាល់ថា សហព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

តើវាមានបញ្ហាសម្រាប់សិស្សរបស់អ្នកដែរឬទេ ប្រសិនបើចុងចោទមិនត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍? អ្នកនឹងកត់សម្គាល់ឃើញថា សៀវភៅដែលអ្នកនឹងប្រើ *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥ - ១៩៧៩)* បាននិយាយពីពាក្យ“ប្រល័យពូជសាសន៍) ហើយពាក្យនេះលេចឡើង នៅពេលអ្នកនិពន្ធសរសេរអំពី“បូជនីយដ្ឋានប្រល័យពូជសាសន៍” ។ ឥឡូវនេះអ្នកដឹងពី

មូលហេតុហើយ ។ "បទឧក្រិដ្ឋកម្មធ្ងន់ធ្ងរ" គឺជាប្រភេទមួយដែលអ្នកអាចគិតទៅដល់តង់មួយយ៉ាងធំដែលចងភ្ជាប់ទៅនឹងសសរបីយ៉ាងរឹងមាំ ៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាមធ្ងន់ធ្ងរ ។ វាមិនមានបញ្ហាអ្វីធ្ងន់ធ្ងរទេ ប្រសិនបើចុងចោទត្រូវបានកាត់ទោសដោយឈរនៅក្រោមតង់មួយនេះ ពីព្រោះពួកគេប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទោះជាឧក្រិដ្ឋកម្មមួយណាក៏ដោយ ក៏ជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតនៅលើពិភពលោក ។ ដូច្នេះ នៅពេលយើងបង្រៀនសិស្សរបស់យើងពីអំពើរបស់ខ្មែរក្រហម យើងនឹងជួយពួកគេឲ្យយល់ពីអត្ថន័យពីរ ៖ (១) តើខ្មែរក្រហមធ្វើអ្វីខ្លះមកលើប្រជាជនខ្លួនឯង (២) ហេតុអ្វីបានជាពួកគេធ្វើដូច្នេះ ។ នៅពេលយើងធ្វើដូច្នេះ យើងកំពុងតែបង្រៀនសិស្សរបស់យើងពីភាពខុសគ្នារវាងសង្គមមួយដែលអាស្រ័យលើតម្លៃរបស់មនុស្សនិងសិទ្ធិរបស់បុគ្គល និងសង្គមមួយដែលដាក់តម្រូវការរបស់សមូហភាពពីលើសិទ្ធិរបស់បុគ្គល ។ ហើយនៅពេលយើងពន្យល់អំពីមូលហេតុដែលខ្មែរក្រហមធ្វើដូច្នេះ ប្រការនេះនឹងជួយលើកទឹកចិត្តពួកគេ ។ យើងកំពុងតែជួយសិស្សឲ្យយល់ពីលទ្ធផល ដែលកើតចេញមកពីការអះអាងក្នុងការស្វែងរកសង្គមល្អឥតខ្ចោះមួយ ដែលមិនឲ្យតម្លៃទៅលើប្រពៃណី និងដែលអះអាងថាពួកគេនឹងចាប់ផ្តើមប្រវត្តិសាស្ត្រសាជាថ្មីម្តងទៀត ។ ខ្ញុំសង្ឃឹមថា អ្នកនឹងយល់ស្របថាមេរៀននេះមានសារសំខាន់ ប្រសិនបើយើងចង់សម្រេចបាននូវ«សង្គមល្អប្រសើរ»មួយ គឺមិនត្រឹមតែនៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅកាណាដាទៀតផង ។ ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់អ្នក ។